RAC Ratings

របាយការណ៍វាយតម្លៃទ្វភាពសង
លេខ: ០១០/២៦
ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៦

ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអឺហ្សិត

ចំណាត់ថ្នាក់ឥណទាន		ព័ត៌មានសញ្ញាបណ្ណ	
ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន	**khA**	ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khAAA**
ទស្សនវិស័យ	**ស្ថិរភាព**	ទំហំ	**១០ លានដុល្លារអាមេរិក**
ប្រវត្តិនៃការវាយតម្លៃទ្វភាពសង		ចំនួននៃការទូទាត់	**ប្រចាំឆមាស (ការប្រាក់ និងប្រាក់ដើម)**
ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន	**khA**	រយៈពេលឥណប្រតិទាន	**២០/មិថុនា/២០២៩ (មិនមានការទូទាត់សងការប្រាក់និងប្រាក់ដើមរយៈពេល២,៥ឆ្នាំ គិតចាប់ពីថ្ងៃបោះផ្សាយ)**
ទស្សនវិស័យ	**ស្ថិរភាព**	ប្រភេទ	**មិនមានទ្រព្យធានា មានបុគ្គលធានា និង ជាសញ្ញាបណ្ណបែតង**
ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khAAA**	អត្រាគូប៉ុង	**SOFR + ១,៥% ទូទាត់ប្រចាំឆមាស**
កាលបរិច្ឆេទបោះផ្សាយ	**ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០២៤**	បុគ្គលធានា	**Credit Guarantee & Investment Facility (CGIF)**

អ្នកវាយតម្លៃ៖

លោក ពេជ្រ ម៉េងហ៊ុយ
p.menghuy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ២៥០ ៧៧៧

លោក ដូ ដេវីត
z.david@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៧៧៧ ៦៤៣

លោក ពឹង ធៀមហេង
p.theamheng@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៧៧៧ ១៧៨

កញ្ញា រិន មន្នីរ័ត្ន
r.monyroth@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៧៧៧ ៤០៦

ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

យើងរក្សាចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន និងចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណរបស់ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប-ភ្នំពេញ អេសអឺហ្សិត ម.ក (« PPSP» ឬ «ក្រុមហ៊ុន») នៅ «**khA**» និង «**khAAA**» និង ទស្សនវិស័យនៅ «**ស្ថិរភាព**» ។

តាមការយល់ឃើញរបស់យើង ការបញ្ចប់គម្រោងការពង្រីករបស់តំបន់សេដ្ឋកិច្ចពិសេស Royal Group Poipet និងផែនការយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ក្នុងការផ្លាស់ប្តូរ អាជីវកម្មទៅរកប្រភពចំណូលបានដដែលៗ អាចនឹងធ្វើឱ្យមានការប្រសើរឡើងនូវចំណូលនិរន្តភាព និងធ្វើឱ្យមានស្ថិរភាពលំហូរសាច់ប្រាក់ ក្នុងរយៈពេលមធ្យម។ បន្ថែមពីនេះ ក្រុមហ៊ុនបន្តរក្សាបាននូវទំហំដ៏ធំសម្រាប់គាំទ្រដល់ឱកាសក្នុងការបង្កើតប្រាក់ចំណូលនាពេលអនាគត។

បើទោះជាយ៉ាងណាក៏ដោយ យើងជឿជាក់ថាក្នុងដំណាក់កាលនេះ កត្តាភូមិសាស្ត្រនយោបាយដុំវិញបញ្ហាជំលោះព្រំដែនរវាងប្រទេសថៃ និងកម្ពុជា អាចបណ្តាលឱ្យមានហានិភ័យដល់ PPSP នាពេលអនាគត និងទំនុកចិត្តរបស់វិនិយោគិន ជាពិសេសគឺតំបន់សេដ្ឋកិច្ចពិសេស Royal Group Poipet។ បើទោះបីជា PPSP មានស្ថានភាពហិរញ្ញវត្ថុប្រសើរឡើង និងការបង្វែរប្រាក់ចំណូលបន្តក៏ដោយ។ ជារួម យើងរក្សាទស្សនវិស័យនៅ «ស្ថិរភាព»។

ទស្សនវិស័យ

យើងរំពឹងថា ចំណូលរបស់ PPSP នៅតែរក្សាបានភាពវិជ្ជមាន ក្នុងរយៈពេលខ្លី ទៅមធ្យម។ ប៉ុន្តែ ចំណូលនេះនឹងបន្តប្រែប្រួលអាស្រ័យនឹងកត្តាពេលវេលា និងភាពមិនប្រាកដប្រជានៃការលក់ដី។ ក្រៅពីនេះ យើងជឿថា ភាពមិនច្បាស់លាស់នៃ កត្តាភូមិសាស្ត្រនយោបាយនឹងប៉ះពាល់ដល់ទំនុកចិត្តនៃអ្នកវិនិយោគ និងសកម្មភាពពាណិជ្ជកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេស Royal Group Poipet ដោយសារតែទីតាំងក្បែរព្រំដែនកម្ពុជា ថៃ។ បន្ថែមពីនេះ PPSP មានគម្រោងបែងចែកភាគលាភ។ ខណៈដែលស្ថានការណ៍បច្ចុប្បន្នអាចគ្រប់គ្រងបាន ការបន្តបែងចែកភាគលាភ

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.

អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងកាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagency.com.kh
Phone: (+855)23 902 408 Email: info@ratingagency.com.kh

RAC website

ទស្សនវិស័យ(ត)

អាចបង្ហាញពីការកាត់បន្ថយនូវភាពបត់បែនហិរញ្ញវត្ថុ ក្នុងរយៈពេលមធ្យម។ ដូច្នេះយើងរក្សាទស្សនវិស័យ «ស្ថិរភាព»។

កត្តាដែលមានឥទ្ធិពលលើបម្រែបម្រួលការវាយតម្លៃ

ក្នុងករណីបង្កើនចំណាត់ថ្នាក់លុះត្រាតែ ការកែលម្អប្រកបដោយនិរន្តរភាពនៅក្នុងអាជីវកម្មដែលរកចំណូលបានជាដែលៗ និងប្រាក់ចំណេញ ដែលគាំទ្រដោយការបង្កើតប្រាក់ចំណូលកាន់តែរឹងមាំ និងស្ថិរភាពលំហូរសាច់ប្រាក់ នឹងនាំឱ្យយើងពិនិត្យមើលការវាយតម្លៃរបស់យើង។ ក្នុងករណីបន្ទាបចំណាត់ថ្នាក់ គឺអាស្រ័យលើស្ថានភាពមិនល្អនៃទម្រង់ហានិភ័យហិរញ្ញវត្ថុអាចបង្កឱ្យមានការផ្លាស់ប្តូរការវាយតម្លៃ។ លើសពីនេះទៅទៀត ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណត្រូវបានភ្ជាប់ទៅនឹងចំណាត់ថ្នាក់សកលរបស់ CGIF (AA ដោយ S&P Global Ratings)។ ដូច្នេះ យើងអាចពិចារណាបន្ទាបចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ ប្រសិនបើចំណាត់ថ្នាក់សកលរបស់ CGIF ត្រូវបានបន្ទាប។

បញ្ហាដែលត្រូវត្រួតពិនិត្យ

ការគ្រប់គ្រងជីធ្លី និងចំណូលពីការលក់ដី និងប្រភពចំណូលសេវាកម្មផ្សេងទៀត ការបែងចែកភាពលាកនាពេលអនាគត គឺជាបញ្ហាដែលនឹងបន្តតាមដាន ដោយហេតុថា កត្តាទាំងនេះនឹងប៉ះពាល់ដល់សមត្ថភាពក្នុងការទូទាត់បំណុលរបស់ PPSP ។

សេចក្តីសង្ខេបអំពី រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអឹីហ្សិត ម.ក

ទិដ្ឋភាពទូទៅ

ការបញ្ចប់ផែនការពង្រីកតំបន់សេដ្ឋកិច្ចពិសេស Royal Group Poipet និង ផែនការពង្រីកនៅខេត្តកំពង់ធំ បានកាត់បន្ថយបញ្ហាកង្វល់ដែលទាក់ទងនឹងការឆ្លាក់ចុះនៃទំហំដីដែលអាចលក់បាន។ ទោះបីជាក្រុមហ៊ុនកំពុងខិតខំប្រឹងប្រែងធ្វើពិពិធកម្មប្រាក់ចំណូលជាបន្តបន្ទាប់ក៏ដោយ ការលក់ដីធ្លីនៅតែត្រូវបានគេរំពឹងថានឹងនៅតែជាប្រភពចំណូលចម្បងរបស់ PPSP ក្នុងរយៈពេលខ្លី ដល់ មធ្យម។ ដូចនេះ ដំណើរការប្រតិបត្តិការរបស់ក្រុមហ៊ុនអាចបន្តបង្ហាញពីភាពប្រែប្រួលមួយកម្រិត ដោយសារតែពេលវេលា និងវដ្តដែលទាក់ទងនឹងសកម្មភាពលក់ដី។ លើសពីនេះ យើងជឿជាក់ថា ភាពមិនច្បាស់លាស់នៃភូមិសាស្ត្រនយោបាយជុំវិញតំបន់ព្រំដែនថៃ-កម្ពុជា អាចប៉ះពាល់ដល់ទំនុកចិត្តរបស់អ្នកវិនិយោគ និងសកម្មភាពពាណិជ្ជកម្មនាពេលអនាគតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស Royal Group Poipet ។

ការប្រតិបត្តិ

ក្នុងឆ្នាំ ២០២៥ ប្រាក់ចំណូលរបស់ PPSP បានកើនឡើងដល់ ៤១,១ លានដុល្លារអាមេរិក ពី ១៣,១ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២៤ ស្មើនឹងកំណើន ២១៤,៩% ធៀបនឹងឆ្នាំមុន ដែលជំរុញដោយការកើនឡើងនៃការលក់ដីធ្លី ដែលបានមកពីតំបន់សេដ្ឋកិច្ចពិសេស Royal Group Kandal ។ ជាលទ្ធផល ប្រាក់ចំណេញសុទ្ធបានកើនឡើងប្រមាណ ១០៩,៣% ធៀបនឹងឆ្នាំចាស់។ បន្ថែមពីនេះ ទម្រង់ប្រាក់ចំណេញរបស់ PPSP ក៏បានពង្រឹងផងដែរនៅក្នុងឆ្នាំសារពើពន្ធ២០២៥ ស្របនឹង EBITDA Margin ប្រសើរឡើងពី ៩,៦% ក្នុងឆ្នាំ២០២៤ ទៅ ២៤,៤% ក្នុងឆ្នាំ២០២៥ ខណៈដែល ROA និង ROE ប្រសើរឡើងដល់ ៧,៤% និង ១០,៧% រៀងគ្នា។ លើសពីនេះ PPSP បានកត់ត្រាភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៅក្នុងអនុបាតសេវាបំណុល ជាមួយនឹងការគ្របដណ្តប់ការប្រាក់បានប្រសើរឡើងដល់ ៨,៤x ក្នុងឆ្នាំ២០២៥ ពី ១,0x ក្នុងឆ្នាំ២០២៤ ខណៈពេលដែលបំណុលធៀបនឹង EBITDA មានភាពប្រសើរឡើង ០,៩x ក្នុងឆ្នាំ២០២៥ ពី ១១,៣x ក្នុងឆ្នាំ២០២៤ ដែលគាំទ្រដោយ EBITDA កាន់តែរឹងមាំ និងស្ថានភាពសាច់ប្រាក់ប្រសើរឡើង។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងកាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagency.com.kh
Phone: (+855)23 902 408 Email: info@ratingagency.com.kh

RAC website

របាយការណ៍ហិរញ្ញវត្ថុសង្ខេប

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ បានរៀបចំឡើងវិញ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ បានរៀបចំឡើងវិញ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
របាយការណ៍ចំណេញ/ខាត					
ចំណូល	២៨,០៦៥,២៨២	២៦,២៥៨,៥២៦	៦១,៩៦៩,៣៣១	១៣,០៥០,៩៩៦	៤១,១០៧,៤០៨
ចំណេញដុល	១០,៨៤៦,៨៧៣	១០,៨៧៦,៧៨៩	១៨,២៥១,១៣១	៨,៤២១,៦៦២	១៧,៦០៤,៩៦៣
ប្រាក់ចំណេញពីប្រតិបត្តិការ	៤,២៦៦,២០២	៣,៦០៧,៥៨៣	១០,៦០៧,២៨៩	៥,៦៨៤,៣៣៨	៩,២២៧,៩០៦
ចំណេញមុនពេលបង់ពន្ធ	៣,០៥៧,៩៥០	២,៨៥៣,៨៩២	៩,៩៧០,២៨០	៤,៩៦៥,១៧២	៨,៣១០,០៤០
ចំណេញ/(ខាត)ប្រចាំឆ្នាំ	**១,៨៨៣,៥០៨**	**២,០៩១,០៤៣**	**៧,៨៧៧,៣៥៣**	**៣,៨៧៧,៧៥៣**	**៨,១១៥,២៦០**
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
ទ្រព្យសកម្ម					
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	៥,៧១៦,០១៧	៤,២៧៦,២៨៩	៤,១៨៧,០៣៨	១៣,៩៤៥,៧៣៥	១៦,៥៥២,១៦៨
ទ្រព្យសកម្មរយៈពេលខ្លីសរុប	**៦៣,៨៣៦,១១៤**	**៦៧,៤៥៨,០៥៩**	**៧០,៤៥១,៥៧២**	**៦៨,៩៩៩,៥១៨**	**៦៦,៣៩៨,០០៩**
ទ្រព្យសម្បត្តិ រោងចក្រ និង គ្រឿងបរិក្ខារ	១៧,៦៥១,៩៩៦	១៧,៦៨៦,៨៤០	១៤,៦៧២,៨១៣	១២,៤៣៥,៦៨៦	១៣,៦៩២,៥៨០
ទ្រព្យសកម្មរយៈពេលវែងសរុប	**៣៤,០៩១,៦៧៥**	**៤០,៥០៧,២១០**	**៤៣,៨៦៩,០០៧**	**៤០,៨៦២,១១៣**	**៤៣,៨៩៦,០១២**
ទ្រព្យសកម្មសរុប	**៩៧,៩២៧,៧៨៩**	**១០៧,៩៦៥,២៦៩**	**១១៤,៣២០,៥៧៩**	**១០៩,៨៦១,៦៣១**	**១១០,២៩៤,០២១**
បំណុល					
គណទាន និង កម្ចី	៣,៣៧១,៥២៧	៤,៩៥២,០៩២	៤,៦៧១,០១៩	១២,២៣១,២៦៩	១១,៣៣១,៨៧៩
បំណុលរយៈពេលខ្លីសរុប	**២២,០៤៦,៦៩៧**	**៣១,៥៧៨,៨៣៤**	**៣៥,២៧៣,៨៨០**	**២៨,៦១៧,៨៦២**	**២៥,១៩៥,២៨២**
គណទាន និងកម្ចី	១៣,៤៨១,៧១៤	១៣,៥២៨,៨៣៦	៩,៨១៤,៤៤៥	៥,៦២៤,២៨៣	៣,១២៦,៥០៥
បំណុលរយៈពេលវែងសរុប	**២១,៧០១,៧១៤**	**២១,២០០,៨៣៦**	**១៦,៩៣៨,៤៤៥**	**១២,២០០,២៨៣**	**៩,១៥៤,៥០៥**
បំណុលសរុប	**៤៣,៧៤៨,៤១១**	**៥២,៧៧៩,៦៧០**	**៥២,២១២,៣២៥**	**៤០,៨១៨,១៤៥**	**៣៤,៣៤៩,៧៨៧**
មូលធន					
ដើមទុន	៣៥,៩៣៧,៥០០	៣៥,៩៣៧,៥០០	៣៥,៩៣៧,៥០០	៣៥,៩៣៧,៥០០	៣៥,៩៣៧,៥០០
បុព្វលាភភាគហ៊ុន	១៣,៦៧៣,៤៩៣	១៤,៦៨១,៩២១	២១,៦១៧,៣២៨	២៨,៧៣៩,០២៥	៣៥,៥០៤,២១៥
មូលធនសរុប	**៥៤,១៧៩,៣៧៨**	**៥៥,១៨៥,៥៩៩**	**៦២,១០៨,២៥៤**	**៦៩,០៤៣,៤៨៦**	**៧៥,៩៤៤,២៣៤**
បំណុលនិងមូលធនសរុប	**៩៧,៩២៧,៧៨៩**	**១០៧,៩៦៥,២៦៩**	**១១៤,៣២០,៥៧៩**	**១០៩,៨៦១,៦៣១**	**១១០,២៩៤,០២១**
របាយការណ៍លំហូរសាច់ប្រាក់					
សាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការ	១៦,៩០៥,៤០៨	១០,១៧២,០៨៧	១៥,៣៨៦,១៨៤	១,៦២៣,៥៨៦	៩,៧៦៩,៩៨៨
សាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ	(៩,៥១៣,២៥៥)	(១០,៥៧៧,៦៦២)	(៩,៤៣៥,១៦០)	៦,៤៤៦,២៨៣	(១២,៣៩៨,៥០២)
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន	(៣,២៩៨,៧៧០)	(១,០៣៤,១៥៣)	(៦,០៨០,២៣៩)	១,៧២៨,៨៣២	(៤,៧៦៥,០៥៣)
(តំហាយ)/កំណើន សាច់ប្រាក់និងសាច់ប្រាក់សមមូល	**៤,០៩៣,៣៨៣**	**(១,៤៣៩,៧២៨)**	**(១២៩,២៥៥)**	**៩,៧៩៨,៧០១**	**(៧,៣៩៣,៥៦៧)**

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងកាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagency.com.kh
Phone: (+855)23 902 408 Email: info@ratingagency.com.kh

RAC website

និយមន័យចំណាត់ថ្នាក់ឥណទាន

ចំណាត់ថ្នាក់វាយតម្លៃឥណទាន (ចំណាត់ថ្នាក់ជាតិ)			
ចំណាត់ថ្នាក់ជាតិ	**និយមន័យ**		
khAAA	សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	១	ហានិភ័យទាបណាស់
khAA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	២	
khA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៣	ហានិភ័យទាប
khBBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៤	
khBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៥	ហានិភ័យមធ្យម
khB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៦	
khCCC	សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអំណោយផល	៧	ហានិភ័យខ្ពស់
khCC	សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៨	
khC	ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៩	ហានិភ័យខ្ពស់ណាស់
khD	មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់	១០	

សេចក្តីថ្លែងមិនទទួលខុសត្រូវ

ព័ត៌មាន និងទិន្នន័យស្ថិតិនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្តៀងផ្ទាត់ដោយឯកភាព្យទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវច្បាស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះ បង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវច្បាស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានធំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមកាតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការឆ្វេងប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងកក់ង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagency.com.kh
Phone: (+855)23 902 408 Email: info@ratingagency.com.kh

RAC website